**សេចក្តីប្រកាសព័ត៌មានរួមរវាងក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**
**និងអង្គការសុខភាពពិភពលោក**

ភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០១៣

# ជំងឺឆ្កែឆ្កួតនៅតែជាគ្រោះថ្នាក់ផ្នែកសុខភាពសាធារណៈនៅកម្ពុជា

ជំងឺឆ្កែឆ្កួតគឺជាជំងឺមួយឆ្លងដោយវីរុសដែលកើតឡើងលើ មនុស្ស និងពពួកសត្វដែលចិញ្ចឹមកូនដោយទឹកដោះ ដែលមានឈាមក្តៅដទៃទៀត ដែលបណ្តាលឲ្យស្លាប់ស្ទើរតែគ្រប់ករណី។ ជំងឺនេះបានសម្លាប់មនុស្សនិងសត្វយ៉ាងច្រើនក្នុងរយៈពេលជាច្រើនសតវត្សមកហើយ។ ទិវាជំងឺឆ្កែឆ្កួតពិភពលោក ដែលរៀបចំឡើងនៅថ្ងៃទី២៨ ខែកញ្ញា គឺជាការរំលឹកដ៏ខ្លាំងក្លាមួយថា ជំងឺនេះនៅតែជាគ្រោះថ្នាក់ផ្នែកសុខភាពសាធារណៈមួយនៅឡើយ នៅក្នុងតំបន់ជាច្រើនក្នុងពិភពលោក ជាពិសេស នៅអាស៊ី និង អាហ្វ្រិក។

នៅក្នុងប្រទេសកម្ពុជា ជំងឺឆ្កែឆ្កួតគឺជាជំងឺដែលមានជាប្រចាំ និងជាជំងឺដែលត្រូវរាយការណ៍តាមរយៈប្រព័ន្ធតាមដានជំងឺប្រកាសអាសន្ន (CAMEWARN) របស់ក្រសួងសុខាភិបាល ។ យោងតាមការសិក្សាមួយដោយវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា មនុស្សប្រមាណ ៨០០នាក់ ប្រហែលជាបានស្លាប់ដោយជំងឺឆ្កែឆ្កួតក្នុងឆ្នាំ២០០៧។ ឆ្កែគឺជាភ្នាក់ងារផ្ទុកមេរោគចម្បងបំផុត ដែលមានជាង៩៩ភាគរយនៃសត្វទាំងឡាយដែលឆ្លងមេរោគនេះ។ កម្ពុជាមានសត្វឆ្កែច្រើនគួរឲ្យកត់សម្គាល់។ របកគំហើញរបស់វិទ្យាស្ថានប៉ាស្ទ័រនៅកម្ពុជា បង្ហាញថាមានសត្វឆ្កែមួយក្បាលធៀបនឹងមនុស្សប្រហែល ៣នាក់ ដែលនេះជាអត្រាមួយខ្ពស់ជាងប្រទេសជិតខាងពី ៣ ទៅ ៤ ដង។

ដើម្បីប្រារព្ធទិវាជំងឺឆ្កែឆ្កួតពិភពលោក ឆ្នាំ២០១៣ ក្រសួងសុខាភិបាល អង្គការសុខភាពពិភពលោក វិទ្យាស្ថានប៉ាស្ទ័រនៅក្នុងប្រទេសកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ និង វិទ្យាស្ថានស្រាវជ្រាវសុខសត្វ បានសហការរៀបចំយុទ្ធនាការផ្តល់ថ្នាំបង្ការក្នុងទ្រង់ទ្រាយធំមួយសម្រាប់សត្វឆ្កែនៅក្នុងភូមិតាង៉ាល់ ឃុំខ្វិតធំ ស្រុកព្រៃឈរ ខេត្តកំពង់ចាម នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៣។

**ឯកឧត្តម ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល បានមានប្រសាសន៍ថា៖ " *នេះគឺជាកិច្ចខិតខំប្រឹងប្រែងរួមគ្នាមួយ ដើម្បីលើកទឹកចិត្តដល់ការចិញ្ចឹមឆ្កែប្រកបដោយការទទួលខុសត្រូវ ជាផ្នែកមួយនៃកម្មវិធីប្រយុទ្ធនឹងជំងឺឆ្កែឆ្កួតលើមនុស្សនិងលើសត្វឆ្កែគ្រប់ជ្រុងជ្រោយ ដែលបង្កើនការយល់ដឹងអំពីបន្ទុកជំងឺឆ្កែឆ្កួតផងដែរ* " ។

ប្រសិនបើមនុស្សម្នាក់ត្រូវបានសត្វដែលមានមេរោគឆ្កែឆ្កួតខាំ ឬក្រញៅ អង្គការសុខភាពពិភពលោក សូមណែនាំឲ្យលាងរបួសចេញឲ្យស្អាតភ្លាមៗ និងត្រូវមានការពិនិត្យនិងវាយតម្លៃឲ្យបានត្រឹមត្រូវ ពីក្រុមគ្រូពេទ្យដែលមានជំនាញខាងផ្នែកនេះ និងធ្វើការចាក់ថ្នាំបង្ការក្រោយពេលប៉ះពាល់។

វិទ្យាស្ថានប៉ាស្ទ័រនៅកម្ពុជា ក្នុងរាជធានីភ្នំពេញ គឺជាមជ្ឈមណ្ឌលបង្អែកជាតិសម្រាប់ធ្វើរោគវិនិច្ឆ័យដោយប្រើមន្ទីរពិសោធន៍សម្រាប់ជំងឺឆ្កែឆ្កួតលើមនុស្សនិងសត្វ និងបានផ្តល់ការគ្រប់គ្រងក្រោយពេលប៉ះពាល់ដល់អ្នកជំងឺប្រមាណ ២០.០០០នាក់ នៅក្នុងឆ្នាំ២០១២។ អ្នកជំងឺដែលមិនបានទទួលការគ្រប់គ្រងក្រោយពេលប៉ះពាល់បានត្រឹមត្រូវ អាចវិវឌ្ឍទៅជាជំងឺឆ្កែឆ្កួត និងត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យកាល់ម៉ែត ដែលមានទីតាំងស្ថិតនៅជាប់នឹងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា។

គេអាចលុបបំបាត់ជំងឺឆ្កែឆ្កួតនៅក្នុងប្រទេសកម្ពុជាបាន ហើយទិវាជំងឺឆ្កែឆ្កួតពិភពលោកគឺជាការរំលឹកមួយថា ជំងឺឆ្កែឆ្កួតលើមនុស្ស ត្រូវបានលុបបំបាត់ស្ទើរតែអស់ទៅហើយនៅក្នុងតំបន់ផ្សេងៗជាច្រើនក្នុងពិភពលោក តាមរយៈការចាក់ថ្នាំបង្ការទ្រង់ទ្រាយធំដល់សត្វឆ្កែក្នុងស្រុក។ ភស្តុតាងកាន់តែច្រើនបង្ហាញថា ការលុបបំបាត់ជំងឺឆ្កែឆ្កួតថ្នាក់តំបន់គឺអាចធ្វើទៅបានតាមរយៈយុទ្ធនាការប្រចាំឆ្នាំយូរអង្វែង ដើម្បីទទួលបានការគ្របដណ្តប់លើសត្វឆ្កែក្នុង

ទ្រង់ទ្រាយធំ។ ការផ្តល់ថ្នាំបង្ការដល់សត្វឆ្កែ មានតម្លៃត្រឹមតែ កន្លះដុល្លារអាមេរិកប៉ុណ្ណោះសម្រាប់ឆ្កែមួយក្បាល ហើយ ការផ្តល់ថ្នាំបង្ការដល់សត្វឆ្កែគឺជាអន្តរាគមន៍ដ៏មានប្រសិទ្ធភាពមួយ ដើម្បីការពារម្ចាស់ គ្រួសារ និងសហគមន៍ ដោយហេតុថាការព្យាបាលក្រោយពេលឆ្កែខាំគឺមិនចាំបាច់នោះទេ នៅក្នុងតំបន់ដែលគ្មានជំងឺឆ្កែឆ្កួត។

លោកវេជ្ជ. ភិធី វ៉ាន់ម៉ាធែន តំណាងអង្គការសុខភាពពិភពលោកប្រចាំកម្ពុជា បានមានប្រសាសន៍ថា៖ *"ទោះបីជាយ៉ាងណាក្តី ការប្រយុទ្ធនឹងជំងឺឆ្កែឆ្កួតចំពោះសត្វឆ្កែ មិនមែនជាគ្មានបញ្ហាប្រឈមនោះឡើយ។ ចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការផ្នែកវិស័យសុខភាពសាធារណៈនិងសុខភាពសត្វ។ បន្ថែមពីលើនេះ វាជាការសំខាន់ខ្លាំងបំផុតដែលត្រូវមានការប្តេជ្ញាចិត្តផ្នែកនយោបាយនិងការគាំទ្រពីសហគមន៍"*។

នៅក្នុងប្រទេសកម្ពុជា សត្វឆ្កែរស់នៅក្នុងតំបន់ទីក្រុង និងជនបទ ជាពិសេសនៅជិតទីផ្សារដែលងាយរកចំណីអាហារបាន។ សូម្បីតែសត្វឆ្កែដែលមានម្ចាស់ ក៏ដើរតាមផ្លូវដោយសេរីដែរ។

លោកវេជ្ជ. ភិធី វ៉ាន់ម៉ាធែន បានបញ្ជាក់ថា ការប្រយុទ្ធនឹងជំងឺឆ្កែឆ្កួតចាំបាច់ត្រូវពិចារណាពីទស្សនវិស័យថ្នាក់តំបន់ផងដែរ។

លោកបានបន្ថែមថា៖ *"ប្រទេសជិតខាងនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ត្រូវតែធ្វើការរួមគ្នាដើម្បីប្រយុទ្ធនឹងជំងឺនេះ។ សត្វឆ្កែដែលឆ្លងជំងឺដែលមិនទាន់ចេញរោគសញ្ញា នេះអាចត្រូវបានគេដឹកជញ្ជូនតាមម៉ូតូ ទូក ឬរថយន្តក្នុងចម្ងាយឆ្ងាយ ហើយអាចចម្លងជំងឺនេះដល់តំបន់ដែលគ្មានជំងឺឆ្កែឆ្កួតពីមុន"*។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


ក្រសួងសុខាភិបាល
វេជ្ជ. សុខ ទូច ៖ ០១២ ៨៥៦ ៨៤៨
វេជ្ជ. លី សុវ៉ាន់ ៖ ០១២ ៨២៥ ៤២៤

អង្គការសុខភាពពិភពលោក
វេជ្ជ. ភិធី វ៉ាន់ម៉ាធែន ៖ ៨៥៥-២៣ ២១៦ ៦១០
វេជ្ជ. ផត្ញ ស៊ីយុកា ៖ ៨៥៥-២៣ ២១៦ ៦១០